RAC Ratings

របាយការណ៍វាយតម្លៃលទ្ធភាពសង
លេខ: ០០១/២៤
ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក

ចំណាត់ថ្នាក់ឥណទាន		**ព័ត៌មានសញ្ញាបណ្ណ**	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khA**	ទំហំ	១០ លានដុល្លារអាមេរិក
ទស្សនវិស័យ	**ស្ថិរភាព**	ចំនួននៃការទូទាត់	ប្រចាំឆមាស (ការប្រាក់ និងប្រាក់ដើម)
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	រយៈពេលឥណប្រតិទាន	៥ឆ្នាំ(មិនមានការទូទាត់ប្រាក់ដើមរយៈពេល២.៥ឆ្នាំ គិតចាប់ពីថ្ងៃបោះផ្សាយ)
		ប្រភេទ	មិនមានទ្រព្យធានា មានបុគ្គលធានា និង ជាសញ្ញាបណ្ណបៃតង
		អត្រាគូប៉ុង	SOFR + [១៥០-២០០] bps ប្រចាំឆមាស
		បុគ្គលធានា	Credit Guarantee & Investment Facility (CGIF)

អ្នកវាយតម្លៃ៖

លោក ស៊ីសុវត្តិ ចក្រការ CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

កញ្ញា សៀង ដារីយ៉ា
s.darya@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៨៦ ៧៧៧

កញ្ញា ពៅ ស៊ុនវណ្ណដែត
p.sunvandeth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣១៨ ៧៧៧

កញ្ញា លីម អច្ឆរាទេពី
l.achhakratepy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក កង គីមឡេង
k.kimleng@ratingagencyofcambodia.com.kh
(+៨៥៥) ៦១ ៩៦៧ ២២១

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៩៩៣ ៣៣៧

អ្នកស្រី សុង ហេងជូលី
hengjulie.song@3e-fii.com
(+៨៥៥) ៨៩ ២៣៩ ២៤៩

លោក ញាន តុលា
tola.nhean@3e-fii.com

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងផ្តើមការវាយតម្លៃលទ្ធភាពសងរបស់ ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក ("PPSP") ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន (ICR) khA (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ «សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច»។

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរ៖ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ SACP វិភាគទម្រង់ឥណទានតាមរយៈហានិភ័យអាជីវកម្ម និងហានិភ័យហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក ។ ទម្រង់ឥណទានឯករាជ្យ (SACP) របស់ PPSP ចំណាត់ថ្នាក់ khA បង្ហាញពីទម្រង់ «ហានិភ័យទាប»។

កត្តាគាំទ្រខាងក្រៅអាចបង្កើតបានដោយភាគីពាក់ព័ន្ធដូចជា ក្រុមហ៊ុនមេ ឬ ក្រុមហ៊ុនហូលឌីង (Group Support) ឬដោយអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល (Country Support)។ ក្នុងករណី PPSP ទាំង កត្តាគាំទ្រខាងក្រៅ របស់ Group និង Country Support មិនមានភាពរឹងមាំគ្រប់គ្រាន់ ដើម្បីធានាតម្លើងចំណាត់ថ្នាក់ឡើយ ។ ដូច្នេះ ICR នៅរក្សាចំណាត់ថ្នាក់ "khA"។

សញ្ញាបណ្ណនេះទទួលបានការធានាពី CGIF ជាស្ថាប័នពាក់ព័ន្ធរបស់ ADB ដែលទទួលបាន ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន "AA" ដោយ S&P។ តាមទស្សនៈរបស់យើង សេចក្តីព្រាងនៃកិច្ចព្រមព្រៀងធានាបង្ហាញអំពីភាពត្រឹមត្រូវនៃការជំនួសឥណទានពី ICR នៃ PPSP ដោយ ICR នៃ CGIF។ ក្នុងករណីមានការខក-ខានសងបំណុល ម្ចាស់បំណុលត្រូវបានការពារដោយការធានាដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌនៃការទូទាត់អោយទាន់ពេលវេលានូវប្រាក់ដើម និងការប្រាក់ដោយ CGIF។

នៅក្នុងលក្ខខណ្ឌនេះ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ គឺ "khAAA" (ចំណាត់ថ្នាក់ជាតិ) អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានា ពេលចូលជាធរមាន។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

ទស្សនវិស័យ

ប្រាក់ចំណូល របស់ PPSP ត្រូវបានជំរុញដោយសកម្មភាពសេដ្ឋកិច្ចនៅកម្ពុជា និងដោយការប្រែប្រួល តម្លៃដីធ្លី។ នៅខណៈពេលនេះ ទិសដៅរបស់កត្តាទាំងពីរនេះ មានភាពវិជ្ជមាន។ សមត្ថភាពនៃគណៈគ្រប់គ្រងដ៏មានបទពិសោធន៍ ព្រមទាំង ជីឧស្សាហកម្មបម្រុងសម្រាប់ លក់/ជួល ផ្តល់អោយ PPSP នូវភាពងាយស្រួលក្នុងការឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតមាន។ ដូច្នេះ ក្នុងការយល់ឃើញរបស់យើង ទស្សនវិស័យ គឺ "**ស្ថិរភាព**"។

កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ករណីដែលអាចប្រសើរឡើង អាស្រ័យលើ ការធ្វើអោយមានកំណើននៃ ប្រភពប្រាក់ចំណូលផ្សេងទៀតរបស់ PPSP ដែលកាត់បន្ថយការពឹងផ្អែកលើ លំហូរសាច់ប្រាក់ពីការលក់ដី។ ករណីដែលអាចថយចុះ នៅពេលមានឱនភាពនៃកត្តាសេដ្ឋកិច្ច ឬ ការដួលរលំក្នុងទីផ្សារអចលនទ្រព្យ អាចនឹងបង្កអោយមានការពិនិត្យសារឡើងវិញលើការវាយតម្លៃ។ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ ផ្អែកលើចំណាត់ថ្នាក់ជាសកលរបស់ CGIF (AA ដោយ S&P Global Ratings)។ ដូច្នេះ យើងអាចពិចារណាលើការបន្ទាបចំណាត់ថ្នាក់ BCR ប្រសិនបើចំណាត់ថ្នាក់ជាសកលរបស់ CGIF ត្រូវបានបន្ទាប។

បញ្ហាដែលត្រូវត្រួតពិនិត្យ

ការគ្រប់គ្រងនិង ការបំពេញបន្ថែមដីឧស្សាហកម្មបម្រុង ព្រមទាំងចំណូលដែលបង្កើតពីការលក់ដី មានសារៈសំខាន់ណាស់ចំពោះ PPSP ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន។

សេចក្តីសង្ខេបអំពី រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក

ទិដ្ឋភាពទូទៅ

PPSP ចាប់ផ្តើមប្រតិបត្តិការ នៅឆ្នាំ ២០០៦ ក្រោយពីទទួលបានការអនុញ្ញាតពី រាជរដ្ឋាភិបាលកម្ពុជា (RGC) អោយក្លាយជា អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។ អាជីវកម្មចម្បងរបស់ PPSP មានដូចជា ការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ ជួល និង ផ្តត់ផ្តង់សោកម្មដែលពាក់ព័ន្ធព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ SEZ ដែលរួមមាន ការផ្តត់ផ្តង់ និងចែកចាយទឹកស្អាត សោជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សោកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកកខ្វក់ និងសោកម្មដទៃទៀត។ PPSP បានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (CSX) ឆ្នាំ ២០១៦។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុន Inter Logistics (Cambodia) Co., Ltd. ដែលជាសមាជិក ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប បានទិញ រួចកាន់កាប់ភាគហ៊ុនចំនួន ៤៥.០៩% នៃ PPSP។

PPSP គ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ៣ទីតាំង ដូចជា៖ ភ្នំពេញ កណ្តាល និង ប៉ោយប៉ែត។ នៅឆ្នាំ២០២៣ កណ្តាល បង្កើតប្រាក់ចំណូលបានច្រើនជាងគេ ស្មើនិង ៧៧% នៃប្រាក់ចំណូលសរុប ដែលចំណូលទាំងនោះមកពីការលក់ដី បន្តដោយ ភ្នំពេញ ២២% និង ប៉ោយប៉ែត ១% ។ នៅឆ្នាំ២០២២ ភ្នំពេញ បង្កើតបានប្រាក់ចំណូល មួយភាគធំ គឺ (៥៩% នៃចំណូលសរុប) នាំមុខ កណ្តាល ៤០% និងប៉ោយប៉ែត ១% ។

ប្រាក់ចំណូលបានបែងចែកទៅជា៖ ការលក់ដី សោកម្ម សំណង់ និង ការដួលអចលនទ្រព្យវិនិយោគ។ ទោះបីជា ចំណែកនៃចំណូលសរុប អាចប្រែប្រួលច្រើនរាល់ឆ្នាំ ការលក់ដីនៅតែជាការរួមចំណែកដ៏ធំហើយ ច្រើនជាងគេបំផុតប្រមាណ ៦៤% ជាមធ្យមចន្លោះពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២៣ បន្តដោយ សោកម្ម (១៥%) សំណង់ (១២%) និងការដួលអចលនទ្រព្យវិនិយោគ (៩%)។

ការប្រតិបត្តិ

អំឡុងពេលដែលប្រាក់ចំណូល និងប្រាក់ចំណេញពីប្រតិបត្តិការ កំពុងមានការកើនឡើង ប្រាក់ចំណូល និងប្រាក់ចំណេញទាំងនេះមានការប្រែប្រួលយ៉ាងខ្លាំង ពីឆ្នាំ ២០១៨ ដល់ ២០២៣។ ការប្រែប្រួលនេះបណ្តាល មកពី ប្រាក់ចំណូល ដែលបានពីការលក់ដី ជាកត្តាមកពីការសម្រេចចិត្តរបស់ក្រុមហ៊ុន និង ពឹងផ្អែកទៅលើស្ថានភាពទីផ្សារ ។ ទោះជាយ៉ាងណា លើកលែងតែឆ្នាំ ២០១៨ PPSP មានប្រាក់ចំណេញ។ ជាពិសេស ក្រុមហ៊ុន នៅតែរក្សាបានភាពខ្លាំង នូវ "Debt Serviceability" និង "Fixed Charges Coverage" ពីឆ្នាំ ២០១៩ តទៅ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស កូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

	បានរៀបចំឡើងវិញ	បានរៀបចំឡើងវិញ	មិនបានធ្វើសវនកម្ម
	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ			
ទ្រព្យសកម្ម			
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	5,716,017	4,276,289	4,147,034
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**63,836,114**	**67,458,059**	**70,451,572**
ទ្រព្យសម្បត្តិ រោង ចក្រ និង គ្រឿងបរិក្ខារ	17,651,996	17,686,840	14,672,813
ទ្រព្យសកម្មរយៈពេលវែងសរុប	34,091,675	40,507,210	43,869,007
ទ្រព្យសកម្មសរុប	**97,927,789**	**107,965,269**	**114,320,579**
បំណុល			
តំណាងទាន និង កម្ចី	3,371,527	4,952,092	3,169,353
បំណុលរយៈពេលខ្លីសរុប	**22,046,697**	**31,578,834**	**33,772,214**
តំណាងទាន និងកម្ចី	13,481,714	13,528,836	11,316,111
បំណុលរយៈពេលវែងសរុប	**21,701,714**	**21,200,836**	**18,440,111**
បំណុលសរុប	**43,748,411**	**52,779,670**	**52,212,325**
មូលធន			
ដើមទុន	35,937,500	35,937,500	35,937,500
បុព្វលាភភាគហ៊ុន	13,673,493	14,681,921	21,617,328
មូលធនសរុប	**54,179,378**	**55,185,599**	**62,108,254**
	-	-	-
បំណុលនិងមូលធនសរុប	**97,927,789**	**107,965,269**	**114,320,579**

	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
របាយការណ៍លំហូរសាច់ប្រាក់			
សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ	16,905,408	10,172,087	15,386,144
សាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ	(9,513,255)	(10,577,662)	(9,435,160)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	(3,298,770)	(1,034,153)	(6,080,239)
(តំហយ)/កំណើន សាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ	**4,093,383**	**(1,439,728)**	**(129,255)**

	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
របាយការណ៍ចំណេញ/ខាត			
ចំណូល	28,065,282	26,258,526	61,969,331
ចំណេញដុល	10,846,473	10,476,789	18,251,131
ប្រាក់ចំណេញពីប្រតិបត្តិការ	4,266,202	3,607,583	10,607,289
ចំណេញមុនពេលបង់ពន្ធ	3,057,950	2,453,892	9,970,240
ចំណេញ/(ខាត)ប្រចាំឆ្នាំ	**1,883,508**	**2,091,043**	**7,877,353**

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**		
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

សេចក្តីថ្លែងមិនទទួលខុសត្រូវ

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្សាំងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាដាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានដំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងស្ថានភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬទាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤

©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស កុមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia

ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh

Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website